ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១២ លេខ ៦៣ សប្តាហ៍ទី ៤ ថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១២

រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៩៥ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ស៊ីគេតា មីតស៊ូតូចិ (SHIGETA MITSUTOKI) ជនជាតិជប៉ុន សញ្ជាតិជប៉ុន កើតនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ៦០៨៧

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៩៦ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក យ៉ាង ស៊ូភីង (YANG SHU PING) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ៦០៨៨

១៩-៧-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៧១២/៦៩៧ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ចេង បាវឆេង (ZHENG BAOCHENG) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ៦០៨៩

១៤-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧០៥ ស្ដីពី ការតែងតាំងឯកឧត្តម និង លោកជំទាវ ចំនួន ០២ រូប ជាទីប្រឹក្សា និង ជាជំនួយការសម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធាន ព្រឹទ្ធសភា នីតិកាលទី ៣ ៦០៩០

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧១០ ស្ដីពី ការផ្លាស់ប្ដូរក្របខ័ណ្ឌ ពីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិ នាយក្រមការ ថ្នាក់លេខ ២ ទៅក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ នៃក្រសួងបរិស្ថាន ចំនួន ០២ រូប ៦០៩១

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧១១ ស្ដីពី ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការពីវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្ដីការគណៈរដ្ឋមន្ត្រី ចំនួន ០៤ រូប និង ប្ដូរប្រភេទក្របខ័ណ្ឌតាមមុខតំណែង ជូនមន្ត្រីរាជការ ចំនួន ០៦ រូប ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្ដីការគណៈរដ្ឋមន្ត្រីជាករណីពិសេស ៦០៩២

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧១២ ស្ដីពី ការដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ៦០៩៤

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧១៣ ស្ដីពី ការបញ្ចប់មុខតំណែង ឯកឧត្តម ទួន ទុទ្ធី ពីទីប្រឹក្សាក្រសួងធម្មការ និង សាសនា មានឋានៈស្មើ អគ្គនាយក ៦០៩៥

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧១៤ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ថ្នាក់ដឹកនាំ ចំនួន ០២ រូប នៃក្រសួងសាធារណការ និង ដឹកជញ្ជូន ៦០៩៦

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧១៥ ស្ដីពី ការដំឡើងឋានន្តរស័ក្តិ ឯកឧត្តម **ជា ផលរិ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានឋានៈស្មើ អគ្គនាយក ៦០៩៧

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧១៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៧ រូប ៦០៩៨

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧១៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ទីប្រឹក្សាបច្ចេកទេសចិន និង មន្ត្រីភាគីកម្ពុជា ចំនួន ០៧ រូប ៦០៩៩

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧២០ ស្ដីពី ការតែងតាំង លោក និង លោកស្រី ចំនួន ០២ រូប ជា ឧកញ៉ា ៦១០០

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧២១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ លោកវេជ្ជបណ្ឌិត **ហ្វីលីបប៉េត ឡឺម៉ាន់** (Doctor.Philippet Le Moine) ៦១០១

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧២២ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ លោក **ម៉ែន ស៊ីថុន** ៦១០២

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧២៣ ស្ដីពី ការផ្លាស់ឯកឧត្តម **ហើស ស៊ីផន** បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋហ្វីលីពីន វិលចូលប្រទេសវិញ ៦១០៣

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧២៤ ស្ដីពី ការតែងតាំង ឯកឧត្តម **ថាន នឹមឡុង** ជា អនុរដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រី ៦១០៤

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧២៥ ស្ដីពី ការតែងតាំង ឥស្សរជន ចំនួន ០២ រូប ជា អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល ៦១០៥

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧២៦ ស្ដីពី ការកែសម្រួល និង ដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការស៊ីវិល ចំនួន ០៥ រូប ពីអនុមន្ត្រីទៅឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្ដីការគណៈរដ្ឋមន្ត្រី ជាករណីពិសេស ៦១០៦

គ

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧២៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្តម **អេង យ៉ាន** ៦១០៨

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧២៨ ស្តីពី ការតែងតាំងឯកឧត្តម ចំនួន ០៣ រូប ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី ៤ ៦១០៩

២១-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧២៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ ឯកឧត្តម និង លោកជំទាវ ចំនួន ០៣ រូប ៦១១០

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

២៣-៨-២០១២ -អនុក្រឹត្យលេខ ១៣០ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៣២៨ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកសំរោង ខេត្តឧត្តរមានជ័យ ៦១១១

២៣-៨-២០១២ -អនុក្រឹត្យលេខ ១៣១ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.១៦៤ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ៦១១៤

២០-៨-២០១២ -អនុក្រឹត្យលេខ ៩៧៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦១១៧

២១-៨-២០១២ -អនុក្រឹត្យលេខ ៩៨៦ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និង តែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ ៦១១៨

២២-៨-២០១២ -អនុក្រឹត្យលេខ ៩៨៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦១១៩

២២-៨-២០១២ -អនុក្រឹត្យលេខ ៩៨៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦១២០

២២-៨-២០១២ -អនុក្រឹត្យលេខ ៩៨៩ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែងមន្ត្រីរាជការ ៦១២១

២២-៨-២០១២ -អនុក្រឹត្យលេខ ៩៩០ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និង តែងតាំងមន្ត្រីរាជការ ៦១២២

២២-៨-២០១២ -អនុក្រឹត្យលេខ ៩៩១ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែង នាយនគរបាលជាតិ ៦១២៤

២២-៨-២០១២ -អនុក្រឹត្យលេខ ៩៩២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦១២៥

២២-៨-២០១២ -អនុក្រឹត្យលេខ ៩៩៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦១២៦

២២-៨-២០១២ -អនុក្រឹត្យលេខ ៩៩៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦១២៧

២២-៨-២០១២ -អនុក្រឹត្យលេខ ៩៩៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦១២៨

២៣-៨-២០១២ -អនុក្រឹត្យលេខ ៩៩៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦១២៩

២. សារាចរណែនាំ

១៧-៨-២០១២ -សារាចរណែនាំលេខ ០៩ សរណន ស្តីពី នីតិវិធីនៃការប្រឡងប្រជែងដើម្បីប្តូរប្រភេទក្របខ័ណ្ឌរបស់មន្ត្រីរាជការស៊ីវិល ៦១៣០

III_ការងារបណ្ណាក្រសួង

១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៦-៨-២០១២ -ប្រកាសលេខ ៨០១ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យុន ម៉េងគ្រុប បង្កើតរោងចក្រ ផលិតជ័រកៅស៊ូ ៦១៣៣

១៦-៨-២០១២ -ប្រកាសលេខ ៨០២ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូ ថេកស្ទាយ សៅអ៊ីរីង គ្រុប អិលធីឌី បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦១៣៧

១៦-៨-២០១២ -ប្រកាសលេខ ៨០៣ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ីបូ អ៊ីអាយស៊ី ហ្គាមេន មេនូហ្វេកឆើរីង (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦១៤១

១៦-៨-២០១២ -ប្រកាសលេខ ៨០៤ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន កៅវៃ ស្ព័ត បង្កើតរោងចក្រ ផលិតស្បែកជើងកីឡា ៦១៤៥

១៦-៨-២០១២ -ប្រកាសលេខ ៨០៥ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខាលីងតុន (ខេមបូឌា) បង្កើតរោងចក្រ ផលិតស្បែកជើង និង ស្បែកជើងកីឡា ៦១៤៩

១៦-៨-២០១២ -ប្រកាសលេខ ៨០៦ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ីបូ បេស្ដ ប្រដាក់សិន (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦១៥៣

២១-៨-២០១២ -ប្រកាសលេខ ៨២៨ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ជុន ស៊ីង ប្លាស្ទិក ប្រដាក់ បង្កើតរោងចក្រ ផលិតថង់ និង បន្ទះប្លាស្ទិក ៦១៥៧

២១-៨-២០១២ -ប្រកាសលេខ ៨២៩ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីដ ១៥៣ (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦១៦១

២១-៨-២០១២ -ប្រកាសលេខ ៨៣០ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ចាមរ៉ាយ (ខេមបូឌា) ភីធីអ៊ី អិលធីឌី បង្កើតរោងចក្រ ផលិតអង្ករ ៦១៦៥

២១-៨-២០១២ -ប្រកាសលេខ ៨៣១ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យូនីធី ហ្វេសិន ខេមបូ បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦១៦៩

២១-៨-២០១២ -ប្រកាសលេខ ៨៣២ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន តឹក វ៉ង់ ស៊ូ មេធៀរៀល មេនូហ្វេកឆើរីង បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ៦១៧៣

២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៧-៤-២០១១ -លិខិតបញ្ជាក់លេខ ២៣០៧ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេគង្គ តារាធន** ៦១៧៧

២៧-៤-២០១១ -លិខិតបញ្ជាក់លេខ ២៣០៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុគា ម៉ែល ខូ អិលធីឌី** ៦១៧៩

២៧-៤-២០១១ -លិខិតបញ្ជាក់លេខ ២៣១០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថប អាប់ ណេតវើក ខមភេនី អិលធីឌី** ៦១៨១

២៨-៤-២០១១ -លិខិតបញ្ជាក់លេខ ២៣២០ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ខេមតូ ម៉ីធ័រ ខមភេនី** ៦១៨៣

២៨-៤-២០១១ -លិខិតបញ្ជាក់លេខ ២៣២១ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **គូល ចាសនា អ៊ិនវេសមេន ខូ អិលធីឌី** ៦១៨៥

២៨-៤-២០១១ -លិខិតបញ្ជាក់លេខ ២៣២៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អន្តរ ថ្មពេជ្រ វិសេសស៍** ៦១៨៧

២៨-៤-២០១១ -លិខិតបញ្ជាក់លេខ ២៣២៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្គាល ឡូន** ៦១៨៩

២៨-៤-២០១១ -លិខិតបញ្ជាក់លេខ ២៣២៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខមផូស សាគូរ៉ា (ខេមបូឌា)** ៦១៩១

២៩-៤-២០១១ -លិខិតបញ្ជាក់លេខ ២៣៣០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វីឡូយ៉ូ (ខេមបូឌា)** ៦១៩៣

២៩-៤-២០១១ -លិខិតបញ្ជាក់លេខ ២៣៤១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន 8 អ អ៊ិនវេសមេន ហូលឌីង ខូ អិលធីឌី** ៦១៩៥

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ីកេតា មីតស៊ូតូចិ** (SHIGETA MITSUTOKI) ជនជាតិជប៉ុន សញ្ជាតិជប៉ុន កើតថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩០ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស. ១២០៧.៧០២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

លេខ: ៧៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ... ឆ្នាំ២០១២
...រដ្ឋាភិបាល
... សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **យ៉ាង ស៊ូភីង** (YANG SHU PING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៥៧ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៥៩០.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០១២
[illegible] រដ្ឋាភិបាល

...យ សុខា

៣៦០.១២០៧.៧០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៦៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចេង បាវចេង** (ZHENG BAOCHENG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៦៦ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ ៦៥៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១២
អគ្គលេខាធិការ...ទីស្តីការគណៈរដ្ឋមន្ត្រី/ រាជរដ្ឋាភិបាល
ស៊ុយ សុខា

ពរស. ១២០៧.៧០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៤១២/៧០៥

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រមុខរដ្ឋស្តីទី

ត្រាស់បង្គាប់

មាត្រា១ : តែងតាំង :

១- ឯកឧត្តម **អ៊ុំ សារិទ្ធ** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- លោកជំទាវ **ពេជ្រ ពុទ្ធិសាធបុរីនាគី** ជាជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១២

ជូនព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

ហរល.១២០៤.៣៤២

ស្មើនឹងច្បាប់ដើម ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible]
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្លាស់ប្តូរក្របខ័ណ្ឌ ពីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិ នាយក្រមការ ថ្នាក់លេខ ២ ទៅក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ នៃក្រសួងបរិស្ថាន

ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ឋានន្តរស័ក្តិ និងថ្នាក់ថ្មី
១	**គង់ សុផល**	ប	នាយក្រមការ ថ្នាក់លេខ ២	អនុមន្ត្រី ថ្នាក់លេខ ៧
២	**ជាង ប៊ុនថេង**	ប	នាយក្រមការ ថ្នាក់លេខ ២	អនុមន្ត្រី ថ្នាក់លេខ ៧

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ រស. ១២០៩.៧១៧

លេខ ... ច.ល
... ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
... សុខា

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៣៧១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ ពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី មានដូចខាងក្រោម :

ល.រ	គោត្តនាម និង នាម	ភេទ	ឋានន្តរស័ក្តិ និង ថ្នាក់	
			ចាស់	ថ្មី
[illegible]	ឈួន គឹមឆយ	ប	ពីវរមន្ត្រី ថ្នាក់លេខ ១	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
២	ចាន់ ចរិយា	ស	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦
[illegible]	សំ ចណ្ណារ៉ា	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦

៤	ឈរ ស្រីពិន	ស	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦

មាត្រា ២ : ត្រូវបានប្តូរប្រភេទក្របខ័ណ្ឌតាមមុខតំណែង ជូនមន្ត្រីរាជការ ចំនួន ០៦ រូប ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ជាករណីពិសេស មានដូចខាងក្រោម :

ល.រ	គោត្តនាម និងនាម	ភេទ	ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់	
			ចាស់	ថ្មី
១	ប៉ក់សម៉យ សុវិទ្យានី	ស	ពីក្រមការដើមខ្សែ ថ្នាក់លេខ ៣	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
២	មាស ទិបុល	ប	ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៩	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៣	ឆេង សុផារី	ស	ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ១០	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៤	ឆេង ស៊ីថា	ប	ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ១០	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៥	នី ប៊ុនលី	ប	ពីនាយភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ ១	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៦	ហែម យ៉ានី	ស	ពីភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ ១	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ ... ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ សីហា ឆ្នាំ២០១២

អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

សុខា

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៨១២/៧១២

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានដំឡើងឋានន្តរស័ក្តិ ថ្នាក់**ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ:

១- ឧត្តមសេនីយ៍ទោ **តាំ សុខុន** អត្តលេខ ០៣៥១

២- ឧត្តមសេនីយ៍ទោ **ខួន ស្រេង** អត្តលេខ ០៣៥២

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៦. ១២០៧. ៣១៥

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

លេខៈ ៦៨៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឆយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/១៩៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **ទួន ទុន្ធី** ពីទីប្រឹក្សាក្រសួងធម្មការ និងសាសនា មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២ : រាល់បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible] ១២០៤.៧២០

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១២

[illegible] ប.ល
[illegible]
រាជធានីភ្នំពេញ [illegible] ខែសីហា ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ ចំនួន ០២រូប នៃក្រសួងសាធារណការ និងដឹកជញ្ជូន
មានគុណបំណាច់ខ្ពស់ និងស្នាដៃល្អ ក្នុងការដឹកនាំ និងគ្រប់គ្រងវិស័យសាធារណការ
និងដឹកជញ្ជូន សំរេចបានលទ្ធផលល្អប្រសើរ

នូវ

គ្រឿងឥស្សរិយយស ជាតូបការ :

ឯកឧត្តម ស្វួត សំបូរ
ឯកឧត្តម គីម ប៊ូរី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible]. ១២០៨.៧២១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

លេខៈ ៧០៥ ប.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែសីហា ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានៈឯកឧត្តម **ជា ផល្លី** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានឋានៈស្មើ **អគ្គនាយក** ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤០.១២០៩.៧២២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

លេខៈ ៧០៧ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible] ទីស្តីការគណៈរដ្ឋាភិបាល
ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន០៧រូប មានស្នាព្រះហស្ត ស្នាដៃល្អក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតនៅវត្តទួលរវៀង ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ កន្លងមក

នូវ

ក-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

ឯកឧត្តម ឈុន ម៉ិនលី

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

១-ព្រះតេជគុណ សម សុផល

២-លោក ជា សុខលៀង

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-ឯកឧត្តម ជឹម វដ្ឋា

២-លោក គល់ ចន្ទ្រានា

៣-លោក ឆឿន ហុក

៤-លោក កៀម ស្រស់

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចាត ១២០៤.៧២៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៤១ ខែ សីហា ឆ្នាំ ២០១២

លេខ ៧១០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

[illegible] រដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោរាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ទីប្រឹក្សាបច្ចេកទេសចិន និងមន្ត្រីភាគីកម្ពុជា ចំនួន ០៧រូប មានគុណបំណាច់ខ្ពស់ និងស្នាដៃល្អ ក្នុងការសាងសង់ផ្លូវជាតិលេខ៦២ ពីខេត្តកំពង់ធំដល់ទីរួមខេត្តព្រះវិហារ កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :
- ឯកឧត្តម ឃិត មុន្នា

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :
១- ឯកឧត្តម ឈន សុភាព
២- ឯកឧត្តម ម៉ៅ ឡាំង
៣- លោក អ៊ុម សិទ្ធីរ៉ា
៤- លោក ឃុន សុខា

គ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា :
- Mr. TANG JUN

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :
- លោក អ៊ុង ចន្ទ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៧.១២០៥.៧២៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

លេខ: ៧១៦ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
ជ័យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧២០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង :

១- លោកវេជ្ជបណ្ឌិត មាស សារ៉ាន

២- លោកស្រី សៅ សុខណ្ណចន្ទ្រី

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៥៧.១២០៥.៧២៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

លេខ: ៧៩១ ច.ល
ជម្រាបជូនចែក
... ថ្ងៃទី ... សីហា ឆ្នាំ២០១២
... ទីស្តីការគណៈរដ្ឋមន្ត្រី
... សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា

ចំពោះ

លោកវេជ្ជបណ្ឌិត **ហ្វីលីបប៉េត ឡឺម៉ាន់** (Doctor. Philippet Le Moine)
ដែលបានលះបង់កម្លាំងកាយ ចិត្ត ប្រាជ្ញា ពេលវេលា និងធនធានយ៉ាងច្រើន
ដើម្បីបំរើសកម្មភាពមនុស្សធម៌ របស់កាកបាទក្រហមកម្ពុជា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៧.១២០៥.៧២៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

លេខ:៧០៨ ច.ល
ដើម្បីចម្លងចែក
ភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០១២
អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧២២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

ចំពោះ

លោក ម៉ែន ស៊ីថុន

ដែលបានលះបង់កម្លាំងកាយ ចិត្ត ប្រាជ្ញា ពេលវេលា និងធនធានយ៉ាងច្រើន
ដើម្បីបំរើសកម្មភាពមនុស្សធម៌ របស់កាកបាទក្រហមកម្ពុជា

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣រល.១២០៤.៧២៥

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ៦១ ខែ សីហា ឆ្នាំ ២០១២

[illegible]: ៧០៥០.ល
ដើម្បីចម្លងចែក
រាជធានី[illegible] ថ្ងៃទី ២ [illegible] សីហា ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៦៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្លាស់ឯកឧត្តម **ហើស សិរីធន** បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋហ្វីលីពីន វិលចូលប្រទេសវិញ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ៦៩៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible]ទីស្តីការគណៈរដ្ឋមន្ត្រី/រាជរដ្ឋាភិបាល
[illegible] សុខា

៣៦លេ-១២០៤.៧៣០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧២៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង ឯកឧត្តម **ចាន់ គីមឡុង** ជាអនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ហទណ.១២០៧.៧៣១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

លេខ: ៧០៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧២៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឥស្សរជនចំនួន ០២ រូប ជាអនុរដ្ឋលេខាធិការក្រសួងសុខាភិបាល :

១- ឯកឧត្តម **ឈូ អ៊ីម៉េង**

២- លោកជំទាវ **អ៊ី សាម៉ុល**

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible]. ១២០៧. ៧៣២

លេខ: ៧០៦ ច.ល

បានថតចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែ សីហា ឆ្នាំ២០១២

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានកែសំរួល និងដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការស៊ីវិលចំនួន ០៥ រូប ពីអនុមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី **ជាករណីពិសេស** :

១- ឯកឧត្តម **ឡៅ សុខារម្ភ** ពីអនុមន្ត្រីថ្នាក់លេខ ១១ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៦

២- ឯកឧត្តម **ទូច ម៉ិនហ្វូរ** ពីអនុមន្ត្រីថ្នាក់លេខ ១១ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៦

៣- ឯកឧត្តម **ហៃ សេង** ពីអនុមន្ត្រីថ្នាក់លេខ ១៣ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៦

៤- ឯកឧត្តម **យ៉ាន់ ម៉ាន់យ៉ិង** ពីអនុមន្ត្រីថ្នាក់លេខ ១១ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៦

៥- ឯកឧត្តម **ហាស់ ម៉េងហួង** ពីអនុមន្ត្រីថ្នាក់លេខ ១៣ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៦

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ក្រសួងព្រះបរមរាជវាំង

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.រកត.១២០៨.៧៣៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២

លេខ: ៦៨៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ [illegible] សីហា ឆ្នាំ២០១២

[illegible] រដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧២៧

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ចំពោះ

ឯកឧត្ដម អេង យ៉ាន

ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិ មាតុភូមិ ទទួលបានលទ្ធផលល្អប្រសើរ

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

[illegible]

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

លេខ: ៦៩៣ ច.ល
ចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ខែសីហា ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង :

១- ឯកឧត្តម **ខាន់ ម៉ាត់** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី ៤ មានឋានៈស្មើ រដ្ឋមន្ត្រី ។

២- ឯកឧត្តម **សោ សុទ្ធារ៉ាវី** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី ៤ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៣- ឯកឧត្តម **ខួន ពន្លក** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី ៤ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible]. ១២០៧.៧២៩

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

លេខ: [illegible] ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible]រដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧២៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នត្រ័យ ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម និងលោកជំទាវ ចំនួន ០៣រូប ដែលមានស្នាដៃល្អ
និងគុណបំណាច់ធំៗជាច្រើន ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

គ្រឿងឥស្សរិយយស ជាតូបការ :

- ឯកឧត្តម ហ៊ឹម ហានសួង
- ឯកឧត្តម អ៊ុំ មាន
- លោកជំទាវ ហេង ពៅ ខេង សួត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៣៩.១២០៧.៣៣៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

លេខៈ ៧៨៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖១៣០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៣២៨ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកសំរោង ខេត្តឧត្តរមានជ័យ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

មាត្រា១:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៦.៣២៨ (ប្រាំមួយពាន់បីរយម្ភៃប្រាំបី) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ ដើម្បីធ្វើការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម(អំពៅ) ដំណាំផ្សេងៗ និងសាងសង់រោងចក្រកែច្នៃស្ករអំពៅ ដូចមាននៅក្នុងផែនទី និងនិយាមការចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០០៩ របស់អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ ដែលភ្ជាប់ជាមួយនឹងលិខិតលេខ ៩០ដនស/អវទ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០០៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៤
-រាជកិច្ច
-ឯកសារកាលប្បវត្តិ



Projection UTM, zon 48 N Datum WGS 84

ID	Northing	Easting	ID	Northing	Easting
A01			21	1571450.300	361101.708
1	1575325.268	351574.163	A03		
2	1575325.550	357315 188	30	1573974.862	363286.668
3	1571243 807	361086.246	31	1573952.724	363431.356
4	1571025.901	361074.040	32	1570369.307	364531 673
5	1569523.225	361890 466	A04		
6	1569247.812	358507 968	22	1574023.456	362969 078
7	1570317.596	358580.774	23	1573981 474	363243 458
8	1570331 072	350440 643	24	1569956.116	364626.015
9	1570330 323	350207.568	25	1568309.734	364550 683
10	1570324 759	348476 067	26	1567789 760	363586.623
11	1572324 193	348462 934	27	1568012.318	363341 986
12	1572326.216	349572.985	28	1571225.615	362176 041
13	1574023 419	349578.178	29	1572174.026	363276 359
14	1574028 889	351574 937	A05		
15	1574325 678	351576 096	33	1567686.961	363370.181
A02			34	1567420.879	362868.508
16	1575325.567	357656 392	35	1566322.550	362862 979
17	1575325 646	358271.384	36	1566298.962	362376 405
18	1574321 442	358275.950	37	1566297.976	362382 353
19	1574154 025	360969.403	38	1566194 734	362656 235
20	1574123 714	361276.002			

A01	5120.48
A02	310.41
A03	57.18
A04	735.67
A05	104.59
សរុប	6,328.33

ភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩

ប្រធានក្រុមវាស់វែង

បានពិនិត្យត្រឹមត្រូវ

ភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៩

បានឃើញ និង ឯកភាព

ឆ្នាំ ២០០៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣១.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.១៦៤ ហិកតា
ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៖ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និ របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិ នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

មាត្រា១:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ៦.១៦៤(ប្រាំមួយពាន់មួយរយហុកសិបបួន)ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំពង្រ និងឃុំចុងកាល់ ខេត្តឧត្តរមានជ័យ ដើម្បីធ្វើការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម(អំពៅ) ដំណាំផ្សេងៗ និងសាងសង់រោងចក្រកែច្នៃស្ករអំពៅ ដូចមាននៅក្នុងផែនទី និងនិយាមការចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០០៩ របស់អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ ដែលភ្ជាប់ជាមួយនឹងលិខិតលេខ ៩០ដនស/អវទ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០០៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:

